ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាចនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ: ៥៨៨ "ឧ"

ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២២

សំណុំរឿងព្រហ្មទណ្ឌលេខ:៤៣៩៧

ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២១

ស៊ើបសួរលេខ: ៣៣៣៣

ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១

ជំនុំជម្រះលេខ: ២២៧

ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង២ និង៣០ នាទីរសៀល នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

ចៅក្រមជំនុំជិះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌ លេខ ៤៣៩៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **សុភាព** ភេទប្រុស អាយុ២២ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តស្វាយរៀង កំរិតវប្បធម៌ **ថ្នាក់ទី៦** សាសនា ព្រះពុទ្ធ មុខរបរ កម្មករសំណង់ ទីលំនៅមុនពេលឃុំខ្លួនរស់នៅការដ្ឋានសំណង់ ផ្លូវលំ សង្កាត់ភ្នំពេញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **ផល្លី** "រស់" ម្តាយឈ្មោះ [redacted] **ហឿន** "រស់" ប្រពន្ធឈ្មោះ [redacted] **ស្រីលក្ខ** កូន ១នាក់ ជា នីតិជន ទោសពីមុន **គ្មាន**។

-**ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ** (PJ) តាមដីកាបង្គាប់ឱ្យឃុំខ្លួន លេខ**៧៤២៣** "ឡ"ដយង ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

២-ឈ្មោះ [redacted] **ខៅ** ភេទប្រុស អាយុ១៨ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តស្វាយរៀង កំរិតវប្បធម៌ **ថ្នាក់ទី៨** សាសនា ព្រះពុទ្ធ មុខរបរ កម្មករសំណង់ ទីលំនៅមុនពេលឃុំខ្លួនរស់នៅការដ្ឋានសំណង់ ផ្លូវលំ សង្កាត់ភ្នំពេញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **ខា** "រស់" ម្តាយឈ្មោះ [redacted] **សារុន** "រស់" នៅ លីវ ជា នីតិជន ទោសពីមុន **គ្មាន**។

-**ឃុំខ្លួននៅ ពន្ធនាគាររាជធានីភ្នំពេញ** (PJ) តាមដីកាបង្គាប់ឱ្យឃុំខ្លួន លេខ**៧៤២៤** "ឡ"ដយង ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ដោយមាន លោកមេធាវី [redacted] អត្ត

លេខ [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ឈ្មោះ [redacted] **សុភាព** និងឈ្មោះ [redacted] **ខៅ**។

ជាប់ចោទពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ផ្លូវសហព័ន្ធរុស្សី សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

<u>អត្ថហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង២១ និង៣០ នាទី កម្លាំងសមត្ថកិច្ចនៃមន្ទីរប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបនៅចំណុច ផ្លូវសហព័ន្ធរុស្សី សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឃាត់ខ្លួនជនជាប់ចោទ ឈ្មោះ [redacted] **សុភាព** ភេទប្រុស និងឈ្មោះ [redacted] **ខៅ** ភេទប្រុស និងដកហូតវត្ថុតាងថ្នាំញៀន ចំនួន១កញ្ចប់ទម្ងន់ ០,០៦(សូន្យក្បៀសសូន្យប្រាំមួយ)ក្រាម កសាងសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមនីវិធីច្បាប់។

-**បានឃើញ** របាយការណ៍លេខ ៦៣៦ រ.ប.ក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងគ្រឿងញៀន។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣៣៨៨ អ.ឃ.ន ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ ៤៦៤៥ អ.ឃ.ន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ៤៣ "ឡ"ដ.ដ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] **សុភាព** បានឆ្លើយថា កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១ ខ្លួននិងឈ្មោះ [redacted] **ខៅ** បាននាំគ្នាទៅទិញថ្នាំញៀននៅម្តុំក្តាន់ពីរ ពេលទៅដល់ពួកខ្លួនបានទិញថ្នាំញៀន តម្លៃ ២០,០០០(ពីរម៉ឺន)រៀល ពីមនុស្សស្រីម្នាក់ ដែលឈរលក់នៅចំណុចម្តុំវត្តនាគវ័ន្ត ផ្លូវបេតុង សង្កាត់បឹងកក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីទុកសម្រាប់ប្រើប្រាស់ ពេលទិញថ្នាំញៀនបានហើយខ្លួនត្រឡប់មកវិញ ស្រាប់តែជួបនឹងសមត្ថកិច្ចភ្លាមនោះ សមត្ថកិច្ចបានឃាត់ខ្លួនឆែកឆេររកឃើញថ្នាំញៀនចំនួន ១កញ្ចប់តូច។

-ជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** បានឆ្លើយថាកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ ខ្លួននិងឈ្មោះ [redacted] **សុភាព** បាននាំគ្នាទៅទិញថ្នាំញៀននៅម្តុំក្តាន់ពីរ ពេលទៅដល់ខ្លួនបានទិញថ្នាំញៀនតម្លៃ ២០,០០០(ពីរម៉ឺន)រៀល ពីមនុស្សស្រីម្នាក់ ដែលឈរលក់នៅចំណុច ម្តុំវត្តនាគវ័ន្ត ផ្លូវបេតុង សង្កាត់បឹងកក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីទុកសម្រាប់ប្រើប្រាស់ ពេលទិញថ្នាំញៀនបានហើយខ្លួនត្រឡប់មកវិញ ស្រាប់តែជួបនឹងសមត្ថកិច្ចភ្លាមនោះ សមត្ថកិច្ចបានឃាត់ខ្លួនឆែកឆេររកឃើញថ្នាំញៀន ចំនួន ១កញ្ចប់តូច។

-តាមអំណានលទ្ធផលកោសលវិច័យ លេខ **៣៣៥២៩/២១** ម.ព.អជ.ប.ត.ញ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ បានបញ្ជាក់ថាជាសំណាកជាគ្រឿងញៀន ប្រភេទ ម្សៅក្រាម ឈ្មោះ **មេតំហ្វេតាមីន**(ហៅគ្រៅម៉ាទឹកកកឬរអាយ) ដែលមានកម្រិតភាពសុទ្ធ **៧៣,៩៥%** នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា:** ក្រោយពីបានស្តាប់អំណានចម្លើយនាពេលសវនាការ រួចមកឃើញថាមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ដូចការចោទប្រកាន់ ហេតុនេះប្តឹងសុំតម្កល់ដីកាសន្និដ្ឋានស្តាពរ លេខ៤៦៤៥ អ.យ.ន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ ទុកនៅដដែល។

-**លោកមេធាវី** [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ឈ្មោះ[redacted] **សុភាព** និងឈ្មោះ[redacted] **ខៅ** បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ និងស្តាប់ចម្លើយសារភាពរបស់កូនក្តីខ្លួនឃើញថា ពួកគាត់បានសារភាពដឹងកំហុស, ដោយសារតែជីវភាពខ្វះខាតពុំមានមុខរបរអចិន្ត្រៃយ៍ និងពុំមានចំណេះវិជ្ជា និងម្យ៉ាងទៀតកូនក្តីខ្លួនក៏ជាជនរងគ្រោះនៃអំពើគ្រឿងញៀនផងដែរ។ ហេតុនេះសូមលោកចៅក្រមសម្រាលទោស ដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះ។

-ជនជាប់ចោទ ឈ្មោះ[redacted] **សុភាព** បាននិយាយសម្តីចុងក្រោយថា: សុំឲ្យតុលាការសម្រាលទោស។

-ជនជាប់ចោទ ឈ្មោះ[redacted] **ខៅ** បាននិយាយសម្តីចុងក្រោយថា: សុំឲ្យតុលាការសម្រាលទោស។

-**ក្រោយពីបាន** ស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-**ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-**ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានប្តឹងរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-**ក្រោយពីបាន** ស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ។

-**ក្រោយពីបាន** ពិនិត្យលើឯកសារភស្តុតាងនានា។

-**ក្រោយពីបាន** ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

<u>សាលាដំបូងរាជធានីភ្នំពេញ</u>

<u>យល់ឃើញថា</u>

១.កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង២១ និង៣០ នាទី ស្ថិតនៅចំណុច មុខវិហារឥស្លាមផ្លូវបេតុង សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ សមត្ថកិច្ចបានចុះបង្ក្រាបករណី **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ដោយបានធ្វើការឃាត់ខ្លួនជនជាប់ចោទ ឈ្មោះ[redacted] **សុភាព** និងឈ្មោះ[redacted] **ខៅ** ព្រមទាំងចាប់យកវត្ថុតាងថ្នាំញៀនឈ្មោះ **មេតំហ្វេតាមីន** ចំនួន១ កញ្ចប់ទម្ងន់សរុប 0,06(សូន្យក្បៀសសូន្យប្រាំមួយ)ក្រាម។

២.ជនជាប់ចោទ ឈ្មោះ[redacted] **សុភាព** បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ ខ្លួននិងឈ្មោះ[redacted] **ខៅ** បានជិះម៉ូតូទៅទិញថ្នាំញៀននៅមុំក្តាន់ពីរតម្លៃ ២0,000(ពីរម៉ឺន)រៀល ពីមនុស្សស្រីម្នាក់ដែលឈរលក់នៅចំណុចមុំវត្តនាគវ័ន្ត ផ្លូវបេតុង សង្កាត់បឹងកក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីទុកសម្រាប់ប្រើប្រាស់ ពេលទិញថ្នាំញៀនបានហើយខ្លួនត្រឡប់មកវិញ ស្រាប់តែជួបនឹងសមត្ថកិច្ចភ្លាមនោះសមត្ថកិច្ចបានឃាត់ខ្លួន និងឆែកឆេររកឃើញថ្នាំញៀន ចំនួន ១កញ្ចប់តូច។

៣.ជនជាប់ចោទ ឈ្មោះ[redacted] **ខៅ** បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ ខ្លួននិងឈ្មោះ[redacted] **សុភាព** បាននាំគ្នាទៅទិញថ្នាំញៀននៅមុំក្តាន់ពីរ តម្លៃ ២0,000(ពីរម៉ឺន)រៀល ពីមនុស្សស្រីម្នាក់ដែលឈរលក់នៅចំណុចមុំវត្តនាគវ័ន្ត ផ្លូវបេតុង សង្កាត់បឹងកក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីទុកសម្រាប់ប្រើប្រាស់ ពេលទិញថ្នាំញៀនបានហើយ ខ្លួនត្រឡប់មកវិញ ស្រាប់តែជួបនឹងសមត្ថកិច្ចភ្លាមនោះសមត្ថកិច្ចបានឃាត់ខ្លួន និងឆែកឆេររកឃើញថ្នាំញៀនចំនួន ១កញ្ចប់តូច។

៤.វត្ថុតាងថ្នាំញៀនប្រភេទក្រាម ពណ៌សផ្កា មានសារធាតុញៀន **មេតំហ្វេតាមីន** (ហៅក្រៅអាយ ឬម៉ាទឹកកក) ចំនួន០១ កញ្ចប់តូចមានទម្ងន់ ០,០៦(សូន្យក្បៀសសូន្យប្រាំមួយ)ក្រាម ដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** និងឈ្មោះ [redacted] **សុភាព** ជាភស្តុតាងស៊ីសង្វាក់ដែលអាចឱ្យតុលាការជឿបានថាជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** និងឈ្មោះ [redacted] **សុភាព** ពិតជាបានប្រព្រឹត្តបទល្មើសគ្រឿងញៀនប្រាកដមែន។

៥.តាមចម្លើយសារភាពរបស់ជនជាប់ចោទ ឈ្មោះ [redacted] **ខៅ និងឈ្មោះ** [redacted] **សុភាព**, វត្ថុតាងថ្នាំញៀនចំនួន ០១កញ្ចប់ទម្ងន់ ០,០៦(សូន្យក្បៀសសូន្យប្រាំមួយ)ក្រាម និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌អាចបញ្ជាក់បានថាជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** និងឈ្មោះ [redacted] **សុភាព** ពិតជាបានរក្សាទុកថ្នាំញៀន ដើម្បីទុកប្រើប្រាស់ពិតប្រាកដមែន។

៦.វត្ថុតាងថ្នាំញៀនប្រភេទក្រាមពណ៌សផ្កា មានសារធាតុញៀន **មេតំហ្វេតាមីន**(ហៅក្រៅអាយ ឬម៉ាទឹកកក) ចំនួន០១ កញ្ចប់តូចមានទម្ងន់ ០,០៦(សូន្យក្បៀសសូន្យប្រាំមួយ)ក្រាម ដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** និងឈ្មោះ [redacted] **សុភាព** ជាភស្តុតាងស៊ីសង្វាក់ដែលអាចឱ្យតុលាការជឿបានថាជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** និងឈ្មោះ [redacted] **សុភាព** ពិតជាបានប្រព្រឹត្តបទល្មើស រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។

៧.តាមលទ្ធផលកោសលវិច័យគ្រឿងញៀន លេខ **៣៣៥២៩/២១** ម.ព.អជ.ប.គ.ញ ចុះថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថាថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** និងឈ្មោះ [redacted] **សុភាព** ប្រភេទក្រាមម្សៅផ្កាពណ៌ស មានឈ្មោះ **មេតំហ្វេតាមីន** (ហៅក្រៅអាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ **៧៣,៩៥%** នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន។ ថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** និង ឈ្មោះ [redacted] **សុភាព** មានទម្ងន់ **០,០៦ក្រាម** មានកម្រិតភាពសុទ្ធចំនួន $\frac{0,06g \times ៧៣,៩៥}{100} = 0,04$**ក្រាម** ដូច្នេះក្នុងអំពើ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** នេះត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៤០ កថាខណ្ឌទី៤** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨.ជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** និងឈ្មោះ [redacted] **សុភាព** ក្នុងពេលប្រព្រឹត្តបទល្មើសជននេះមានសមត្ថភាពលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវនូវអំពើល្មើសរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

៩.អំពើរបស់ជនជាប់ចោទ ឈ្មោះ [redacted] **ខៅ** និងឈ្មោះ [redacted] **សុភាព** បានបង្ហាញឱ្យឃើញថាគ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្តក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើសជនជាប់ចោទរូបនេះ មានចេតនាទុច្ចរិតដែលការព្រឹត្តនេះធ្វើឱ្យខូចនូវរបៀបរៀបរយសាធារណៈសណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់នីតិានុកូលភាពសង្គម និងបំពានលើមាត្រាដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោះ [redacted] **ខៅ** និងឈ្មោះ [redacted] **សុភាព** ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ផ្លូវសហព័ន្ធរុស្សី សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១.ជនជាប់ចោទ ឈ្មោះ [redacted] ខៅ និងឈ្មោះ [redacted] សុភាព ជាជនក្រីក្រ គ្មានកំរិតវប្បធម៌ ហើយតាមជីវប្រវត្តិកន្លងមក ជនជាប់ចោទរូបនេះពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងណាឡើយ គប្បីតុលាការលើកយកមកពិចារណាក្នុងការផ្តល់ស្ថានសម្រាលទោសខ្លះ ដើម្បីផ្តល់ឱកាសឲ្យជននេះបានកែប្រែខ្លួនឡើងវិញ។

១២.វត្ថុចាប់យកមាន:

១២.១.ថ្នាំញៀនប្រភេទ ក្រាមពណ៌សថ្លា ចំនួន០១ កញ្ចប់តូចទម្ងន់សរុប ០,០៦(សូន្យក្បៀសសូន្យប្រាំមួយ)ក្រាម ដែលសល់ពីការធ្វើតេស្តពិសោធន៍បឋមរួចបានវេចខ្ចប់ដោយមានការទទួលស្គាល់ និងស្នាមផ្តិតមេដៃស្តាំពីជនជាប់ចោទ ឈ្មោះ [redacted] ខៅ និងឈ្មោះ [redacted] សុភាព ត្រូវបានចៅក្រមស៊ើបសួរដកសំណាកយកទៅធ្វើកោសលវិច័យទាំងអស់ពុំមាននៅសល់ទេ ដូច្នេះពុំមានវត្ថុតាងថ្នាំញៀននៅសល់ដែលត្រូវឲ្យតុលាការសម្រេចរឹបអូសនោះទេ។

១២.២.ម៉ូតូចំនួន ១គ្រឿងម៉ាកហុងដា BEAT ពណ៌ ក្រហម ពាក់ស្លាកលេខ ស្វាយរៀង 1P-8265 ដែលបានដកហូតពីជនជាប់ចោទ ឈ្មោះ [redacted] ខៅ ជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ជនជាប់ចោទ គប្បីប្រគល់ឲ្យម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១៣.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានតម្កល់បទចោទប្រកាន់ និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ [redacted] ខៅ និងឈ្មោះ [redacted] សុភាព តាមច្បាប់ ហេតុនេះគប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៤.លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា សូមលោកចៅក្រមសម្រាលទោសដល់កូនក្តីខ្លួនឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] ខៅ ដោយក្តីអនុគ្រោះគប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៥.ជនជាប់ចោទ ឈ្មោះ [redacted] ខៅ និងឈ្មោះ [redacted] សុភាព បានធ្វើសំណូមពរជាសំដីចុងក្រោយថាសុំឲ្យតុលាការសម្រាលទោស ហេតុនេះគប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

<u>ហេតុដូច្នេះសម្រេច</u>

១.ផ្តន្ទាទោស

១.១.ឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ២២ ឆ្នាំ សញ្ជាតិ ខ្មែរ ដាក់ពន្ធនាគារកំណត់ ០២(ពីរ)ឆ្នាំ តែទោសនេះអនុវត្តទោសក្នុងពន្ធនាគារចំនួន ១(មួយ)ឆ្នាំ ទោសលើសពីនេះត្រូវព្យួរសាកល្បងក្នុងរយៈពេល ១(មួយ)ឆ្នាំ តាមបញ្ញត្តិមាត្រា ១១៧, មាត្រា១១៨ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ៤,០០០,០០០(បួនលាន)រៀល។

១.២.ឈ្មោះ [redacted] ខៅ ភេទប្រុស អាយុ១៨ ឆ្នាំ សញ្ជាតិ ខ្មែរ ដាក់ពន្ធនាគារកំណត់ ០២(ពីរ)ឆ្នាំ តែទោសនេះអនុវត្តទោសក្នុងពន្ធនាគារចំនួន ១(មួយ)ឆ្នាំ ទោសលើសពីនេះត្រូវព្យួរសាកល្បងក្នុងរយៈពេល ១(មួយ)ឆ្នាំ តាមបញ្ញត្តិមាត្រា១១៧, មាត្រា១១៨ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ៤,០០០,០០០(បួនលាន)រៀល។

ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ផ្លូវសហព័ន្ធរុស្សី សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ក្នុងរយៈពេលព្យួរទោសសាកល្បងទណ្ឌិត ឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] ខៅ ត្រូវគោរព:

២.១.វិធានការណ៍ត្រួតពិនិត្យ

២.១.១.ទណ្ឌិតត្រូវគោរពតាមដីការកោះរបស់ព្រះរាជអាជ្ញា ឬ បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។

២.១.២.ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យរបស់បុគ្គលដែលព្រះរាជអាជ្ញា បានប្រគល់អំណាចឲ្យ។

២.១.៣.ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬ បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យនូវឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឲ្យរស់នៅក្នុងសង្គមវិញ។

២.១.៤.ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។

២.១.៥.ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។

២.១.៦.ទណ្ឌិតត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាមុនពេលធ្វើដំណើរទៅបរទេស។

២.២.អនុវត្តកាតព្វកិច្ច

២.២.១.ទណ្ឌិតត្រូវទទួលឲ្យពេទ្យធ្វើការពិនិត្យ និងព្យាបាល។

២.២.២.ទណ្ឌិតមិនត្រូវសេពគប់ជាមួយបុគ្គលដែលប្រើប្រាស់ថ្នាំញៀននិងជួញដូរថ្នាំញៀន។

៣.វត្ថុចាប់យកប្រគល់ឲ្យម្ចាស់ដើមវិញមាន: ម៉ូតូចំនួន ១គ្រឿង ម៉ាកហុងដាBEAT ពណ៌ក្រហម ពាក់ស្លាកលេខ ស្វាយរៀង 1P-8265 ប្រគល់ ឈ្មោះ [redacted] ខៅ វិញ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ **ខែមីនា ឆ្នាំ២០២២** ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] **សុភាព** និងឈ្មោះ [redacted] **ខៅ**។ ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា: [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខានិងត្រា: [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]